EIE-06-256 REEPRO

# ការជំរុញប្រសិទ្ធភាពប្រើប្រាស់ថាមពលថ្មី

# នៅប្រទេសកំពុងអភិវឌ្ឍន៍

## ការប្រើប្រាស់ថាមពលទាក់ទងទៅវិស័យ សេដ្ឋកិច្ច សង្គមកិច្ច

## នៅតំបន់ជនបទ ក្នុងប្រទេសកម្ពុជា

**រៀបរៀងដោយៈ**

លោក ជោ គឹមហេង

លោក សំ ផល្លា

លោក ថាច ជីតារ៉ូ

អង្គការកែឆ្នៃសំរាម និងការសិក្សានៅកម្ពុជា

មិថុនា ២០០៧

The REEPRO project receives funding from the European Commission within the COOPENER Programme.
The contents of this document are the sole responsibility of the authors and can under no circumstances be regarded as reflection of the position of the Europe Union.

# មាតិកា

1 ការបង្ហាញ ... 1
1.1 ពត៌មានទូទៅ ... 1
2 ពត៌មានវិស័យថាមពល (ទិន្នន័យច្បាស់លាស់) ... 1
2.1 ការវិភាគស្ថានភាព ... 1
2.2 ទីប្រជុំជន (ក្រុងភ្នំពេញ) ... 5
2.3 ជនបទ ... 6
2.4 សក្តានុពលលើការប្រើប្រាស់ថាមពលថ្មី ... 6
2.4.1 ជីវម៉ាស់ ... 6
2.4.2 ថាមពលព្រះអាទិត្យ PV ... 7
2.4.3 ថាមពលខ្យល់ ... 8
2.4.4 ថាមពលវារីអគ្គិសនីខ្នាតតូច ... 8
2.5 ការទទួលស្គាល់ប្រើប្រាស់ថាមពលថ្មី ... 10
3 ពត៌មានតាមការចុះធ្វើបញ្ជីសំណួរស្ទាបស្ទង់ ... 12
3.1 ក្រុមគោលដៅ ... 12
3.1.1 ភេទ Gender ... 12
3.1.2 ប្រភពចំណូលសំខាន់សំរាប់គ្រួសារនិមួយៗ ... 13
3.1.2.1 ខេត្តពោធិ៍សាត់ ... 13
3.1.2.2 ខេត្តកំពង់ឆ្នាំង ... 13
3.1.2.3 ខេត្តស្វាយរៀង ... 14
3.1.2.4 ខេត្តកំពង់ចាម ... 14
3.1.2.5 តារាងប្រៀបធៀប ... 14
3.1.3 តំបន់រស់នៅផ្សេងៗគ្នា ... 16

3.2 ទិន្នន័យសង្គមកិច្ច-សេដ្ឋកិច្ច ....16
3.2.1 ចំណូលគ្រួសារតាមក្រុមគោលដៅផ្សេងគ្នា ....18
3.2.2 ទំហំគ្រួសារ ....20
3.2.3 កម្រិតនៃការអប់រំទៅតាមក្រុមគោលដៅ ....21
3.2.4 អត្រាចេះអានអក្សរតាមគ្រួសារ ....28
3.2.5 ប្រភពនៃថាមពល ....31
3.2.6 ការចំណាយទៅប្រភពថាមពលផ្សេងៗគ្នា ....34
3.2.7 តំលៃនៃធនធានថាមពលផ្សេងគ្នា ....38
3.2.8 ពេលបែងចែកសំរាប់ប្រមូលឧស (តាមស្ត្រី បុរស និងក្មេង) ....39
3.2.9 ថាមពលប្រើចុងក្រោយ ....40
3.2.10 បញ្ហាសុខភាព ....41
3.2.11 ចំណេះដឹងនៃការបង្កើតថាមពលឡើងវិញ ....41
4 សេចក្តីបន្ថែម ....42
4.1 សេចក្តីបន្ថែមទី១: ទំរង់នៃរបាយការណ៍ ....42
4.2 សេចក្តីបន្ថែមទី២: បញ្ជីសំណួរ ....47
5 ឯកសារយោង ....56

## តារាងរូបភាព


រូបភាពទី១: ប្រភពចំណូលក្នុងចំណោមក្រុមគោលដៅតាមខេត្តទាំងបួននៅកម្ពុជា............................15

រូបភាពទី២: អត្រាភាពក្រីក្រទៅតាមតំបន់ក្នុងប្រទេសកម្ពុជា........................................................17

រូបភាពទី៣: ទំហំគ្រួសារនៅតាមតំបន់ក្នុងប្រទេសកម្ពុជា............................................................20

រូបភាពទី៤: ការអប់រំនៃសមាជិកគ្រួសារជាមួយនិងប្រភពចំណូលផ្សេងៗគ្នាក្នុងខេត្តពោធិ៍សាត់...........22

រូបភាពទី៥: ការអប់រំនៃសមាជិកគ្រួសារជាមួយនិងប្រភពចំណូលផ្សេងៗគ្នាក្នុងខេត្តពោធិ៍សាត់ និងការប្រៀបធៀបរវាងកំរិតការសិក្សារបស់បុរស និងស្ត្រី....................................................23

រូបភាពទី៦: កំរិតនៃការអប់រំក្នុងគ្រួសារជាមួយនឹងប្រភពចំណូលផ្សេងៗគ្នា នៅខេត្តស្វាយរៀង...........24

រូបភាពទី៧: កំរិតនៃការអប់រំក្នុងគ្រួសារជាមួយនឹងប្រភពចំណូលផ្សេងៗគ្នា នៅខេត្តស្វាយរៀង...........25

រូបភាពទី៨: កំរិតនៃការសិក្សានៃបុរស និងស្ត្រីនៅក្នុងខេត្តស្វាយរៀង............................................25

រូបភាពទី៩: កំរិតនៃការអប់រំក្នុងគ្រួសារជាមួយនឹងប្រភពចំណូលផ្សេងៗគ្នា នៅខេត្តកំពង់ឆ្នាំង............26

រូបភាពទី១០: កំរិតការសិក្សានៃបុរស និងស្ត្រីនៅខេត្តកំពង់ឆ្នាំង....................................................27

រូបភាពទី១១: កំរិតនៃការអប់រំក្នុងគ្រួសារជាមួយនឹងប្រភពចំណូលផ្សេងៗគ្នា នៅខេត្តកំពង់ចាម..........28

រូបភាពទី១២: កំរិតនៃការសិក្សានៃបុរស និងស្ត្រីនៅខេត្តកំពង់ចាម..................................................28

រូបភាពទី១៣: អត្រាអ្នកចេះអានអក្សរនៃបុរស និងស្ត្រី តាមតំបន់ផ្សេងៗគ្នានៃខេត្តផ្សេងៗគ្នា យោងទៅតាមបញ្ជីសំណួររបស់ COMPED......................................................................29

រូបភាពទី១៤: អត្រាអ្នកចេះអានអក្សរនៃបុរស និងស្ត្រី តាមតំបន់ផ្សេងៗគ្នានៃខេត្តពោធិ៍សាត់ យោងទៅតាមបញ្ជីសំណួររបស់ COMPED.............................................................29

រូបភាពទី១៥: អត្រាអ្នកចេះអានអក្សរនៃបុរស និងស្ត្រី តាមតំបន់ផ្សេងៗគ្នានៃខេត្តស្វាយរៀង យោងទៅតាមបញ្ជីសំណួររបស់ COMPED......................................................................30

រូបភាពទី១៦: គ្រួសារជាមួយការប្រើប្រាស់ពេញលេញ នៅតំបន់ផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា...............33

រូបភាពទី១៧: តំលៃថាមពលសំរាប់គ្រួសារកសិករ និងអ្នកសិប្បករក្នុង១ខែ ខុសគ្នាទៅតាមស្រុក។..36

រូបភាពទី១៨: តំលៃថាមពលសំរាប់ការប្រើប្រាស់របស់គ្រួសារគ្រូបង្រៀនក្នុង១ខែ ក្នុងស្រុកខុសគ្នា។ តំលៃប្រើប្រាស់ថាមពលសរុបស្មើរតែ ១១០ ដុល្លា ក្នុង១ខែ ក្នុង១គ្រួសារ។..................36

រូបភាពទី១៩: តំលៃថាមពលសំរាប់ការប្រើប្រាស់របស់គ្រួសារអ្នកជំនួញខ្នាតតូច ១ខែ ក្នុងស្រុកខុសគ្នា។ តំលៃប្រើប្រាស់ថាមពលសរុបស្មើរតែ ១៦០ ដុល្លា ក្នុង១ខែ ក្នុង១គ្រួសារ។..................37

រូបភាពទី២០: តំលៃថាមពលសំរាប់ការប្រើប្រាស់របស់គ្រួសារមន្ត្រីរាជការធុន ១ខែ ក្នុងស្រុកខុសគ្នា។ តំលៃប្រើប្រាស់ថាមពលសរុបស្មើរតែ ៣៩០ ដុល្លាអាមេរិក ក្នុង១ខែ ក្នុង១គ្រួសារ។......38

រូបភាពទី២១: ពេលវេលាដែលបែងចែករាល់ថៃដល់ ស្ត្រី បុរស និងកុមារ សំរាប់រកប្រមូលឧស ......39

រូបភាពទី២២: ឧសប្រើសំរាប់ចំអិនអាហារទៅតាមខេត្តផ្សេងៗនៅកម្ពុជា..........................................40

# បញ្ជីតារាង

តារាង១: កំលាំងថាមពលតំឡើងសរុបរបស់ EDC និងការប្រើប្រាស់កំរិតអតិបរមាគិតជា MW..........2

តារាង២: តំរូវការថាមពល និងការព្យាករណ៍ទុកជាមុននៅប្រទេសកម្ពុជា.......................................2

តារាង៣: តំរូវការថាមពល និងការព្យាករណ៍ជាមុនដោយលំអិតនៅប្រទេសកម្ពុជា...........................2

តារាង៤: តំលៃរចរាចរភ្លើងជាផ្លូវការ.............................................................................................3

តារាង៥: កំលាំងភ្លើងប្រើប្រាស់នៅភ្នំពេញ......................................................................................5

តារាង៦: សក្តានុពលភាពនៃការបង្កើតប្រភពថាមពលថ្មី.........................................................10

តារាង៧: ប្រជាពលរដ្ឋនៅតាមខេត្ត..............................................................................................12

តារាង៨: ចំនួនអ្នកដែលត្រូវបានធ្វើសម្ភាសន៍នៅខេត្តពោធិ៍សាត...................................................13

តារាង៩: ចំនួនអ្នកដែលបានធ្វើសម្ភាសន៍នៅខេត្តកំពង់ឆ្នាំង........................................................13

តារាង១០: ចំនួនអ្នកដែលបានធ្វើសម្ភាសន៍នៅខេត្តស្វាយរៀង......................................................14

តារាង១១: ចំនួនអ្នកដែលបានធ្វើសម្ភាសន៍នៅខេត្តកំពង់ចាម.......................................................14

តារាង១២: ចំនួនអ្នកដែលបានធ្វើសម្ភាសន៍នៅខេត្តទាំងបួន........................................................14

តារាង១៣: អត្រាចំណូលជាមធ្យមក្នុងមួយគ្រួសារ ....................................................................18

តារាង១៤: មធ្យមភាគទំហំគ្រួសារក្នុងខេត្តទាំងបួន.......................................................................21

តារាង១៥: កំរិតនៃការសិក្សានៅខេត្តពោធិ៍សាត់ ........................................................................22

តារាង១៦: កំរិតនៃការសិក្សានៅខេត្តស្វាយរៀង...........................................................................24

តារាង១៧: កំរិតនៃការសិក្សានៅខេត្តកំពង់ឆ្នាំង ........................................................................26

តារាង១៨: កំរិតនៃការសិក្សានៅខេត្តកំពង់ចាម...........................................................................27

តារាង១៩: ប្រភពនៃការប្រើប្រាស់ថាមពលជាមធ្យម.....................................................................31

តារាង២០: ការចំណាយលើប្រភពថាមពលផ្សេងៗ ......................................................................34

1

# 1 ការបង្ហាញ

## 1.1 ពត៌មានទូទៅ

ព្រះរាជាណាចក្រកម្ពុជាមានទីតាំងស្ថិតនៅតំបន់អាស៊ីអគ្នេយ៍ដែលមានព្រំប្រទល់ជាប់ ថៃ ឡាវ និង វៀតណាម។ មានព្រំប្រទល់ ៨០០គីឡូម៉ែត ជាប់ជាមួយថៃនៅផ្នែកខាងលិច ៤៥០គីឡូម៉ែតព្រំប្រទល់ ជាប់ជាមួយឡាវនៅផ្នែកខាងជើង ១២៥០គីឡូម៉ែតជាប់ជាមួយវៀតណាម នៅផ្នែកខាងកើត និង៤៤៣ គីឡូម៉ែត ជាប់ឈូងសមុទ្រថៃ។ ប្រទេសកម្ពុជាមានផ្ទៃក្រឡា ១៨១,០៣៥ គីឡូម៉ែតការ៉េ ដែលមាន ២៤ ខេត្ត-ក្រុង មានន័យថា ២០ខេត្ត និង ៤ ទីក្រុងធំៗដូចមានក្រុងភ្នំពេញ ក្រុងប៉ៃលិន ក្រុងព្រះសីហនុ និងក្រុងកែប។ តាមការប៉ាន់ប្រមាណចំនួនប្រជាជនក្នុងឆ្នាំ២០០៦ គឺ ១៤,៩៧១,០០០ ដែលខុសពីឆ្នាំ ១៩៩៨ ចំនួន ៣,៥៣៣,៣៨៤ នាក់។




# 2 ពត៌មានវិស័យថាមពល (ទិន្នន័យច្បាស់លាស់)

## 2.1 ការវិភាគស្ថានភាព

អគ្គិសនីកម្ពុជា Electricié du Cambogde (EDC) ដែលមានរដ្ឋជាម្ចាស់ ជាអាជ្ញាធរផលិត បញ្ជូននិងចែកចាយថាមពលភ្លើងទូទាំងកម្ពុជា។ បណ្តាញភ្លើង៦ខេត្ត តភ្ជាប់បញ្ចូលទៅ EDC ទន្ទឹមពេលដែលកំលាំងប្រើប្រាស់ថាមពលមួយចំនួននៅតាមខេត្តស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ហើយក្រោមការចូលរួមត្រួតពិនិត្យជាមួយអាជ្ញាធរខេត្ត។ EDC មានអតិថជនសរុបក្នុងពេលបច្ចុប្បន្ន ១៨៤,៩១៨នាក់ ដែលខុសពីឆ្នាំ ១៩៩៩ ចំនួន ១០៣ ៤៧៣នាក់។ នៅពេលបច្ចុប្បន្នតិចជាង ១៥% នៃអ្នករស់នៅកម្ពុជាបានប្រើប្រាស់ភ្លើងក្នុងម្នាក់ៗជារៀងរាល់ឆ្នាំ ៤៥គីឡូវ៉ាត់

ប្រើតិចជាងគេក្នុងចំណោមអាស៊ានបួពាំ។ សរុបកំលាំងថាមពលរបស់ EDC ១៥៨.៤ (MW) មេកាវ៉ាត់ ជាមួយនឹងការប្រើប្រាស់ជាក់ស្តែងជាអតិបរមាត្រឹមតែ ១២៤ (MW) មេកាវ៉ាត់ក្នុងឆ្នាំ ២០០៣។

**តារាង១: កំលាំងថាមពលតំឡើងសរុបរបស់ EDC និងការប្រើប្រាស់កំរិតអតិបរមាគិតជា MW**

| ផ្នែក/ឆ្នាំ | ២០០៣ | ២០០២ | ២០០១ | ២០០០ | ១៩៩៩ |
|---|---|---|---|---|---|
| កំលាំងថាមពលបានតំឡើង | ១៥៨.៤ | ១៥៧.៤ | ១៣៧.៣៩ | ១២២.៤ | ១១៩.៨ |
| អតិបរមាក្នុងការបញ្ចេញ | ១២៤ | ១២៣ | ១១២.៥ | ៩៧.៥ | ៩៧ |

មណ្ឌលដែលសំខាន់នៅក្នុងការប្រើប្រាស់ភ្លើងគឺនៅទីក្រុងភ្នំពេញ មានចំនួនបួនភាគប្រាំនៃធនធានភ្លើងរបស់ EDC និងមួយភាគប្រាំជាការប្រើប្រាស់ភ្លើងនៅតាមខេត្ត។ សរុបកំលាំងថាមពលផលិតដោយ EDC នៅតាមខេត្តមានតែ ៣៤មេកាវ៉ាត់ជាមួយការប្រើប្រាស់ជាក់ស្តែងជាអតិបរមាត្រឹមតែ ២៣ មេកាវ៉ាត់។

**តារាង២: តំរូវការថាមពល និងការព្យាករណ៍ទុកជាមុននៅប្រទេសកម្ពុជា**

| ផ្នែក/ឆ្នាំ | ២០០៤ | ២០០៦ | ២០០៨ | ២០១០ | ២០១២ | ២០១៤ | ២០១៦ |
|---|---|---|---|---|---|---|---|
| **កំលាំង, MW** | ២៧៣ | ៣៣១ | ៤០៤ | ៤៧៧ | ៥៥៨ | ៦៥១ | ៧៤៦ |
| **ថាមពល , GWh** | ១០៣៦ | ១២១៥ | ១៤៥៤ | ១៧០០ | ១៩៦៨ | ២២៩២ | ២៦៣៤ |

តំរូវការនៃការប្រើប្រាស់ត្រូវគណនាទៅតាមការកើនឡើងជាមធ្យម ១៨% ក្នុង១ឆ្នាំៗប្រៀបធៀបទៅ ១២ឆ្នាំក្រោយ ហើយតំរូវការជាក់ស្តែងត្រូវបានរំពឹងទុកថាអាចឡើងដល់ ៧៤៦ (MW) មេកាវ៉ាត់នៅក្នុងឆ្នាំ២០១៦ ជាមួយនឹងការកើនឡើងខ្លាំងពីភ្នំពេញ។

**តារាង៣: តំរូវការថាមពល និងការព្យាករណ៍ជាមុនដោយលំអិតនៅប្រទេសកម្ពុជា**

| ផ្នែក/ឆ្នាំ | ២០០៤ | ២០០៦ | ២០០៨ | ២០១០ | ២០១២ | ២០១៤ | ២០១៦ |
|---|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | ១០.០ | ១២.០ | ១៤.៥ | ១៧.៣ | ២០.០ | ២៤.០ | ២៦.០ |
| បាត់ដំបង | ១២.០ | ១៥.០ | ១៨.៥ | ២២.៤ | ២៧.០ | ៣១.០ | ៣៣.០ |
| កំពង់ចាម | ១៣.០ | ១៥.២ | ១៧.៩ | ២០.៥ | ២៣.០ | ២៦.០ | ២៩.០ |
| កំពង់ឆ្នាំង | ២.៨ | ៣.៤ | ៤.០ | ៤.៧ | ៥.០ | ៦.០ | ៧.០ |
| កំពង់ស្ពឺ | ៣.៨ | ៤.៧ | ៥.៩ | ៧.២ | ៩.០ | ១២.០ | ១៦.០ |
| កំពង់ធំ | ៤.៥ | ៥.៣ | ៦.៤ | ៧.៥ | ៩.០ | ១០.០ | ១១.០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| កំពត | ១០.១ | ១៣.៩ | ១៦.៣ | ១៨.៩ | ២៥.០ | ២៨.០ | ៣៣.០ |
| កណ្តាល | ៦.៧ | ៧.៩ | ៩.២ | ១០.៦ | ១២.០ | ១៣.០ | ១៥.០ |
| កោះកុង | ១.៤ | ១.៧ | ២.០ | ២.៣ | ៣.០ | ៣.០ | ៤.០ |
| ក្រចេះ | ៥.៧ | ៦.៨ | ៨.០ | ៩.៤ | ១១.០ | ១២.០ | ១៤.០ |
| មណ្ឌលគីរី | ០.៤ | ០.៥ | ០.៦ | ០.៧ | ១.០ | ១.០ | ១.០ |
| ភ្នំពេញ | ១៧០.០ | ២០៧.០ | ២៥៦.០ | ៣០៤.០ | ៣៥៧.០ | ៤១៩.០ | ៤៨៣.០ |
| ព្រះវិហារ | ១.០ | ១.១ | ១.៤ | ១.៦ | ២.០ | ២.០ | ២.០ |
| ព្រៃវែង | ៥.៥ | ៦.៨ | ៧.៨ | ៩.០ | ១០.០ | ១១.០ | ១៣.០ |
| ពោធិ៍សាត់ | ៤.២ | ៥.០ | ៥.៩ | ៦.៩ | ៨.០ | ៩.០ | ១១.០ |
| រតនគីរី | ១.៥ | ១.៧ | ១.៩ | ២.២ | ២.០ | ៣.០ | ៣.០ |
| សៀមរាប | ៧.១ | ៨.៤ | ១០.០ | ១១.៥ | ១៣.០ | ១៥.០ | ១៧.០ |
| ក្រុងព្រះសីហនុ | ៤.៨ | ៥.៥ | ៦.៣ | ៧.៣ | ៨.០ | ១០.០ | ១១.០ |
| ស្ទឹងត្រែង | ០.៩ | ១.១ | ១.៣ | ១.៥ | ២.០ | ២.០ | ២.០ |
| ស្វាយរៀង | ២.៨ | ៣.២ | ៣.៩ | ៤.៤ | ៥.០ | ៦.០ | ៦.០ |
| តាកែវ | ៤.២ | ៤.៩ | ៥.៨ | ៦.៧ | ៨.០ | ៨.០ | ៩.០ |
| សរុប | ២៧២.៤ | ៣៣១.០ | ៤០៣.៦ | ៤៧៦.៦ | ៥៥៨.០ | ៦៥១.០ | ៧៤៦.០ |

ទន្ទឹមនឹងEDC មិនមានលទ្ធភាពអាចបំពេញសេចក្តីត្រូវការភ្លើងដែលចេះតែកើនឡើង គោលនយោបាយភ្ជាប់បណ្តាញប្រើប្រាស់ភ្លើងទៅតាមតំបន់ដែលអត់មានបណ្តាញ និងត្រូវបានលក់ភ្លើងទៅអោយផងដែរពី IPPs (អ្នកផ្គត់ផ្គង់ថាមពលឯករាជ្យ) សំរាប់ចែកចាយបន្ត ក្រោមកិច្ចព្រមព្រៀងជាមួយ PPA ក្នុងតំលៃ ៨.៧ សេន ក្នុង១គីឡូវ៉ាត់ម៉ោង។ ក្រោម PPA មានក្រុមហ៊ុនឯកជនបី ដែលកំពុងបានប្រើប្រាស់ភ្លើងរបស់ EDC ភ្នំពេញមានឈ្មោះ Cambodia Utility Pte.Ltd., Jupiter Cambodia and Cambodia International Hydropower Development Co. Ltd។

**តារាង៤: តំលៃរចរាចរភ្លើងជាផ្លូវការ**

| **ឯកតា** | | **Riel/kWh** | **US$/kWh** |
|---|---|---|---|
| | **០_៥០ kWh** | ៣៥០ | ៩ សេន |
| ភ្នំពេញ | **៥១_១០០ kWh** | ៥៥០ | ១៤សេន |
| | **> ១០០ kWh** | ៦៥០ | ១៦សេន |
| ក្រុងព្រះសីហនុ | | ៥០០ | ១៣សេន |

| | | | |
|---|---|---|---|
| កំពង់ឆ្នាំង | | ៨៥០ | ២១សេន |
| តាកែវ | | ៩០០ | ២៣សេន |
| បាត់ដំបង | | ៩៦០ | ២៤សេន |
| រដ្ឋាភិបាល | | ៧០០ | ១៧សេន |
| អតិថិជន | ការិយាល័យអង្គការ<br>ផ្ទះបរទេស<br>ស្ថានទូត | ៨០០ | ២០សេន |
| អ្នកជំនួញ | ជំនួញខ្នាតតូច | ៦៥០ | ១៦សេន |
| | ជំនួញធុនកណ្តាល | ៦០០ | ១៥សេន |
| | ជំនួញធុនធំ | ៥០០ | ១៣សេន |
| | អ្នកលក់ភ្លើង | ៤៨០ | ១២សេន |
| ឧស្សាហកម្ម និងសិប្បករ | ជំនួញធុនតូច | ៦៥០ | ១៦សេន |
| | ជំនួញធុនកណ្តាល | ៥៥០ | ១៤សេន |
| | ជំនួញធុនធំ | ៥០០ | ១៣សេន |
| | អ្នកលក់ភ្លើង | ៤៨០ | ១២សេន |

ឆ្នាំ២០០៧ កម្ពុជាត្រូវនាំភ្លើងចូលពីវៀតណាម។ មានតំលៃតាមការប៉ាន់ស្មានគឺ ៦.០២ សេនក្នុង១គីឡូវ៉ាត់ម៉ោងហើយអាចលក់ចេញបាន ៨.៥សេន ក្នុង ១គីឡូវ៉ាត់ម៉ោង បន្ទាប់ពីបន្ថែមតំលៃពី EDC។ តំលៃភ្លើងបច្ចុប្បន្ននៃ EDC គឺ ១២.៥ សេន ក្នុងមួយគីឡូវ៉ាត់ ម៉ោង។ ហើយតំលៃចរាចរភ្លើងជាផ្លូវការ គឺរវាងពី ៩សេន ក្នុង១គីឡូវ៉ាត់ម៉ោងក្នុងភ្នំពេញ និង២៤សេន ក្នុង ១គីឡូវ៉ាត់ម៉ោង ក្នុងខេត្តបាត់ដំបង។ វាស្ថិតក្នុងចំណោមតំលៃខ្ពស់បំផុតនៅអាស៊ាន។ EDC មិនទាន់បានផ្តល់ការប្រើប្រាស់ភ្លើងដល់កន្លែងអ្នកដែលរស់នៅ ដោយ ខុស ច្បាប់ និង តំបន់ សមាគមន៍ អ្នក ក្រី ក្រនៅឡើយ ។ អ្នក ដែលមិនសូវ មានកំរៃ បានបង្ខំខ្លួន ទិញ ភ្លើង ពី អ្នក ចែកចាយឯក ជន ក្នុងតំលៃ ១៦សេន ក្នុង មួយ គីឡូវ៉ាត់ ម៉ោង។ តាមការស្រាវជ្រាវ អ្នកចែកចាយភ្លើងឯកជនត្រូវលក់ភ្លើងជាអប្បរមា ២៥០ គីឡូវ៉ាត់ម៉ោង និងជាអតិបរមា ៥០០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ។

## 2.2 ទីប្រជុំជន (ក្រុងភ្នំពេញ)

ទីក្រុងភ្នំពេញជាកន្លែងដែលមានអ្នកប្រើប្រាស់ភ្លើងដ៏សំខាន់នៃប្រទេសកម្ពុជា តាមការគណនាអោយដឹងថា ជាង៨១.៥% នៃអ្នកប្រើប្រាស់ភ្លើងក្នុងប្រទេស។ ថាមពលភ្លើងដែលបានតំឡើងសំរាប់ទីក្រុងសរុប ១២៤ មេកាវ៉ាត់ និងការប្រើប្រាស់ជាអតិបរមាជាក់ស្តែងតែ ១០១ មេកាវ៉ាត់ នៃការតំលើងកំលាំងភ្លើងសរុប ១២៤ មេកាវ៉ាត់ ក្នុងទីក្រុងភ្នំពេញ។ IPPs. (អ្នកផ្គត់ ថាមពល ឯក រាជ្យ) ក្រោម ការ គ្រប់ គ្រង PPA ប្រើប្រាស់ភ្លើងអស់ ៦៣ (MW) មេកាវ៉ាត់។

**តារាង៥: កំលាំងភ្លើងប្រើប្រាស់នៅភ្នំពេញ**

| Sn. | Plant | Capacity in MW |
|---|---|---|
| 1. | C2 | 18 MW |
| 2. | C3 | 15.4 MW |
| 3. | C4 | 2 x 5 MW |
| 4. | C5 | 3 x 6 MW |
| 5. | C6 | 5 x 7 MW |
| 6. | IPP - 1: Cambodia Utility Pte. Ldt. | 5 x 7 MW |
| 7. | IPP - 2: Jupiter Cambodia | 10 x 1.5 MW |
| 8. | IPP - 3: Cambodia Internationa Hydropower Development Co. Ltd. | 2 x 6 MW |

សំរាប់អ្នកប្រើប្រាស់ភ្លើងលើសពី ៥០គីឡូវ៉ាត់ម៉ោងតារាងតំលៃកើន ៩សេនដុល្លាអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង។ ហើយ ១៦សេនដុល្លាអាមេរិកក្នុង មួយគីឡូវ៉ាត់ម៉ោងសំរាប់អ្នកប្រើប្រាស់ដែលលើសពី 100 គីឡូវ៉ាត់ ម៉ោង ។ គេធ្វើយ៉ាងនេះក្នុង បំណង ជួយ ផ្តល់ ផល ចំណេញ ដល់ អ្នក ក្រ។ អ្នក ក្រ ដែល បានភ្ជាប់បណ្តាញភ្លើងរបស់ EDC ទោះជាយ៉ាងណា នៅតែបង់តំលៃខ្ពស់ទៅលើភ្លើង។ ពួក ឈ្មួញ បានទិញតំលៃភ្លើងពី EDC ក្នុងតំលៃ ១៦សេន ក្នុង១គីឡូវ៉ាត់ហើយលក់វិញក្នុងតំលៃពី ២២ សេនដុល្លាអាមេរិកទៅ ៥០ សេនក្នុង១គីឡូវ៉ាត់ម៉ោងទៅអោយអ្នកស្រុក។ ការទិញភ្លើងពីអ្នកលក់ភ្លើងឯកជនក្នុងតំលៃខ្ពស់ក៏ដោយសារតែពួកគេ មិន មាន កិច្ចសន្យា អ្វី ជាមួយ EDC ហើយ ពួកគេ ត្រូវ បង់ ១៦ សេន ក្នុង ១ គីឡូវ៉ាត់ម៉ោង ពីព្រោះពួកគេទិញភ្លើងប្រើប្រាស់លើសពី ១០០ គីឡូវ៉ាត់ម៉ោង ពីបណ្តាញភ្លើង EDC។ EDC នៅភ្នំពេញមានអតិថជន ១៤០ ៩១៨ នាក់ (ប្រមាណជា ៥៩% នៃអ្នករស់នៅក្នុងទីក្រុង)ដែលប្រើប្រាស់ ៨៨.៤៥% (៤៧៨.១GWh) នៃថាមពលលក់នៅកម្ពុជា(៥៤០GWh)។ ស្ទើរតែពាក់កណ្តាល (៤៧.៥%) នៃ ចំនួន ថាម ពល សរុប ដែល លក់ នៅ ភ្នំពេញ មក ពី អតិថជន ដែល មានលំនៅដ្ឋាន ទី នោះ ហើយ ២៣.០៩% គឺ អ្នក ជំនួញ និង១២.៤៤ គឺ តំរូវការ ឧស្សាហកម្ម ។ បីភាគ បួននៃ អ្នក ប្រើប្រាស់ភ្លើងនៅភ្នំពេញទាំងអស់ក្នុងប្រទេសនៅតែប្រើឧស និងធ្យូង ដែលនាំចូលពីជាយក្រុង និងជុំវិញតំបន់ជនបទ ជាហេតុនាំអោយមានការប៉ះពាល់បរិស្ថានទៅទីកន្លែងដែលនាំឧសមក។

## 2.3 ជនបទ

តាមជនបទនៅកម្ពុជាគេនៅតែប្រើប្រាស់ប្រភពថាមពលតាមទំលាប់ ដូចជាការប្រើធ្យូង និងឈើ។ តំរូវការឈើសំរាប់ដុត។ ៨៤% នៃប្រភពថាមពល ដំបូងដ៏សំខាន់ ។ ការប្រើប្រាស់ឧស មិនត្រឹមតែ នៅតាមជនបទទេ ប៉ុន្តែគេប្រើវាផងដែរទៅតាមទីក្រុង និងសំរាប់ធ្វើការលក់ដូ និងតំរូវការឧស្សាហកម្ម។

## 2.4 សក្តានុពលលើការប្រើប្រាស់ថាមពលថ្មី

### 2.4.1 ជីវម៉ាស់

ប្រភពនៃកំលាំងថាមពលមួយដែលជាធនធានយើងមានស្រាប់សំណល់ជីវម៉ាស់។ ជីវម៉ាស់សំរាប់កំលាំងអគ្គិសនីមានតួនាទីសំខាន់ក្នុងយុទ្ធសាស្រ្តនៃការចែកភ្លើងក្នុងជនបទ។ វិស័យឯកជនដែលទាក់ទងទៅនឹងជីវម៉ាស់សំរាប់កំលាំងអគ្គិសនី ក៏មានលក្ខណៈសំខាន់ផងដែរសំរាប់ការអភិវឌ្ឍន៍ថាមពលនៅជនបទ ។ យោងទៅតាមទ្រឹស្តីនៃថាមពលជីវម៉ាស់សំរាប់ឆ្នាំ ២០០៥ មានឡើងដល់ទៅ ៧00 មេកាវ៉ាត់។ នាពេលបច្ចុប្បន្នទោះបីជាគ្មានការផលិតភ្លើងមកពីឈើ ឧស ជាមូលដ្ឋានក៏ដោយ មានជំនួយពី NEDO (2004) បានត្រូវសាងសង់ជីវឧស្ម័នមួយ (២ខ៣៥កី) និងថាមពលព្រះអាទិត្យ PV 50kWp។
ការប្រើប្រាស់ជាទូទៅនៃឈើ និងជីវម៉ាស់ផ្សេងទៀតនៅប្រទេសកម្ពុជាគឺមានសង្ខេបដូចតទៅៈ

- ៩៤%នៃឧសឈើប្រើប្រាស់ដោយផ្ទាល់
- ៦%នៃឧសឈើដុតបំលែងទៅជាធ្យូង
- ៩០%នៃការប្រើប្រាស់ឧសសរុបគឺត្រូវបានអនុវត្តដោយផ្ទាល់តាមរយៈគ្រួសារនៅតាមតំបន់ជនបទ
- ៨%នៃការប្រើប្រាស់ឧសសរុប គឺត្រូវបានប្រើទៅតាមតំបន់ទីក្រុងផ្សេងៗ
- តិចជាង១%នៃការប្រើប្រាស់ឧសសរុប គឺត្រូវប្រើនៅក្នុងវិស័យឧស្សាហកម្ម
- តិចជាង១%នៃការប្រើប្រាស់ឧសសរុប គឺត្រូវប្រើប្រាស់ជាសេវាកម្ម
- ជីវម៉ាស់ផ្សេងៗដូចជាឈើ អាចម៍រណា និងអង្កាម គឺត្រូវបានប្រើតាមការដុតក្នុងឡសំរាប់អ្នកលក់នំប៉័ង ការចំអិនអាហារ
- សំបកឈើរ្បមែកឈើ ត្រូវបានដុតសំរាប់ដុតធ្វើស្ករអំពៅ និងស្ករត្នោត
- ស្រកីដូង សំបកដូង និងអង្កាមត្រូវបានប្រើសំរាប់ចំអិនម្ហូបអាហារ និងចំណីសត្វផ្សេងៗ
- នៅ តាម ផ្ទះគ្រួសារជនបទមួយ ចំនួន ប្រើ ធាងដូង ធាងត្នោត អង្កាម លាយជាមួយ អាចម៍គោ ចំបើង និងកំទេចឈើ សំរាប់ចំអិនអាហារ។

## 2.4.2 ថាមពលព្រះអាទិត្យ PV

បច្ចេកវិទ្យា. PV. នៅក្នុងប្រទេសកម្ពុជា ត្រូវបាន ធ្វើការអភិវឌ្ឍន៍ ដោយសន្សឹមៗ បំផុត ហើយកំពុង ស្ថិតនៅក្នុងជំហ៊ានស្រាវជ្រាវនិងអភិវឌ្ឍ សំរាប់ធ្វើការបង្ហាញជាចំបង។ នៅក្នុងប្រទេសកម្ពុជា ការប្រើប្រាស់បច្ចេកវិទ្យាថាមពលព្រះអាទិត្យ PV បានចាប់ផ្តើមតាំងពីឆ្នាំ១៩៩៧ សំរាប់ការផ្តល់ពន្លឺ ប្រើវិទ្យុទូរទស្សន៍ និងប្រព័ន្ធទំនាក់ទំនងតាមជនបទ ។ ការតំឡើងសរុបមានប្រមាណជាង ១000 kwp .ហើយ ត្រូវបាន តំឡើងជាចំបងនៅលើ ស្ថានីយ៍ ទំនាក់ទំនង នៅក្នុងតំបន់ ជនបទ ។ ប្រព័ន្ធ ថាមពល ព្រះអាទិត្យ នៅ តាម គេហដ្ឋានភាគច្រើនបំផុត (SHS) ជាមួយចរន្ត ១២.V/.៥0_៧0 Ah.នៃកំលាំងអាគុយដែលជា លទ្ធផល គំរោងឧបត្ថម្ភ ដោយ SIDA, NBDO, UNICEF, FONDEM. និង អ្នកឧបត្ថម្ភ ផ្សេងៗ ទៀត ព្រមទាំង អ្នកឧបត្ថម្ភជាសមាជិកគ្រួសារបងប្អូនដែលរស់នៅប្រទេសបារាំង កាណាដា និងសហរដ្ឋអាមេរិក។ឧបករណ៍ទាំងអស់នេះត្រូវបាននាំចូល និងសំរាប់ធ្វើការបង្ហាញ។

ខាងក្រោមនេះគឺជាគំរោងថាមពលព្រះអាទិត្យមួយចំនួនៈ

គំរោងឧបត្ថម្ភដោយអាល្លឺម៉ង់តាមរយៈ (CDG) ដែលផ្តល់ការ បណ្តុះ បណ្តាលសំរាប់បច្ចេកវិទ្យា ថាមពលព្រះអាទិត្យ_ជីវម៉ាស់_ការថែរក្សាប្រតិបត្តិប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ។

ភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស្វីស (SIDA) បានជួយឧបត្ថម្ភកម្មវិធីស្រាវជ្រាវលើប្រព័ន្ធថាមពលព្រះអាទិត្យ (PV) សំរាប់សំងួត ថាមពលជីវម៉ាស់ ព្រះអាទិត្យ briquette stove។ SIDA ក៏បានផ្តល់ការឧបត្ថម្ភសំរាប់តំឡើងប្រព័ន្ធថាមពលព្រះអាទិត្យ SHS ជាមួយកំលាំងថាមពល ១២៤0 Wp។

អង្គការអភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម និងថាមពលថ្មី របស់ប្រទេស ជប៉ុន(NEDO) បានជួយ ឧបត្ថម្ភ ដល់ការតំឡើងប្រព័ន្ធថាមពលព្រះអាទិត្យ សំរាប់បញ្ចូលអាគុយ និងប្រើ អណ្តូងស្នប់ ដែល មានកំលាំងសរុប ៣២៧៦ Wp។ NEDO ក៏បានឧបត្ថម្ភ ផងដែរ សំរាប់ ការ ស្ថាបនា គំរោងសាកល្បងប្រព័ន្ធ hybrid សំខាន់ចំនួន ២, ទី១ គឺថាមពល ព្រះ អាទិត្យ និងថាមពលមីក្រូវ៉ារីអគ្គិសនី (80kwp+40kw) និងមួយទៀតថាមពលព្រះអាទិត្យ និង Biogass (៥0គីផ + ៦0គី) និងរួមបញ្ចូលទាំងប្រព័ន្ធ បណ្តាញភ្លើងខ្នាតតូច ដែលប្រព័ន្ធទាំងនេះត្រូវបានដាក់អោយដំណើរការរួចហើយកាលពីខែកក្កដា ឆ្នាំ២00៤ ។

មជ្ឈមណ្ឌលសុខភាព FONDEM បានផ្តល់ការឧបត្ថម្ភសំរាប់ការតំឡើងប្រព័ន្ធថាមពលព្រះអាទិត្យនៅក្នុងមជ្ឈមណ្ឌលសុខភាពតាមជនបទចំនួន ៤៥កន្លែងចាប់តាំងពីឆ្នាំ ១៩៩៩_២00២ ហើយក៏បានធ្វើការអភិវឌ្ឍន៍ការតំឡើងប្រព័ន្ធថាមពលព្រះអាទិត្យគំរូមួយដែលរួមមានពន្លឺ ១៧0 Wp វិទ្យុ និងទូរទឹកកកដើម្បីកាត់បន្ថយតំលៃចំណាយ សំរួលការថែទាំ។

### 2.4.3 ថាមពលខ្យល់

ឧបសគ្គដ៏ចំបង ចំពោះការវាយតំលៃសក្តានុពលថាមពលខ្យល់គឺកង្វះទិន្នន័យដែលអាចជឿជាក់បាន សំរាប់ទំរង់រយៈពេលខ្លី និងរយៈពេលវែង។ ការអង្កេតអំពីអាកាសធាតុ នៅតែមានលក្ខណៈអាក់ខាន និងមានកំរិតនៅប្រទេសកម្ពុជា ។ ដើម្បីគណនាលក្ខខណ្ឌខ្យល់សំរាប់តំបន់និមួយៗនៅក្នុងប្រទេសកម្ពុជា NEDO (2002) បានប្រើលក្ខណៈចំរុះនៃស្ថានភាពភូមិសាស្ត្ររួមជាមួយទិន្នន័យអាកាសធាតុពិភពលោកបានមកពីការិយាល័យអាកាសធាតុប្រទេសអង់គ្លេស ។ នៅភាគខាងត្បូងនៃបឹងទន្លេសាបតំបន់ភាគនិរតីនិងតំបន់ឆ្នេរសមុទ្រភាគខាងត្បូងមានលក្ខខណ្ឌខ្យល់អំណោយផលល្អ។

The Wind Atlas of south East Asia ផលិតដោយកម្មវិធី ASTAE របស់ធនាគារពិភពលោកក្នុងឆ្នាំ ២០០១ គឺជាការសិក្សាដែលមានលក្ខណៈសក្តានុពលបំផុតនៃប្រភពធនធានខ្យល់ដែលធ្លាប់បានធ្វើឡើងនៅក្នុងតំបន់នេះ។ វាបានបង្ហាញអត្តសញ្ញាណលើផ្ទៃដីប្រមាណ ៦២០០គម$^{២}$ នៅក្នុងប្រទេសកម្ពុជាដែលមានល្បឿនខ្យល់មធ្យម ៦m/s។ នៅតាមតំបន់តូចៗមានល្បឿន ៧m/s។លក្ខណៈខុសប្លែកគ្នានៃសេដ្ឋកិច្ចគំរោងដែលមានសក្តានុពល ត្រូវបានកំណត់ដោយកត្តាជាក់លាក់នៃទីកន្លែងមួយចំនួន ដូចជាភាពនៅជិតតំបន់បញ្ជូនសារ និងតំលៃដឹកជញ្ជូន ។ ប៉ុន្តែវាមានសារៈសំខាន់ណាស់ក្នុងការកំណត់សំគាល់ថាការបង្កើតខ្យល់ដែល មានសារៈសំខាន់ត្រូវបានបង្កើតឡើងនៅប្រទេសជាច្រើនដែលមានល្បឿនខ្យល់ ប្រហាក់ប្រហែលគ្នា និងប្រទេសកម្ពុជា។ ភាពខុសប្លែកគ្នានៃគំរោងផ្សេងៗនៅប្រទេសកម្ពុជា នឹងត្រូវជ្រោមជ្រែងដោយតំលៃអគ្គិសនីខ្ពស់បំផុតរបស់ប្រទេសកម្ពុជាបានមកពីប្រភពប្រេងឥន្ធនៈហ្វូសីល។

ការផ្តល់ហិរញ្ញវត្ថុ និងការជួយឧបត្ថម្ភនៃគំរោងបែបនេះគឺកំពុងតែលេចឡើងជាមួយគំរោងផ្សេងៗផងដែរ ដូចជាមូលនិធិចរន្តអគ្គិសនីតំបន់ជនបទរបស់ធនាគារពិភពលោក World Bank's Rural Electrification Fund ព្រមទាំងការចូលរួមដែលមានសក្តានុពល នៅក្នុងផ្នែកមេកានិកអភិវឌ្ឍភាពស្អាត និងតំបន់រមណីយដ្ឋានដែលកំពុងពេញនិយម ។ ការផ្តល់នូវតំរូវការនៅតាមតំបន់ឆ្នេរសមុទ្រ នៅជុំវិញទីក្រុងព្រះសីហនុ ការបង្កើតអគ្គិសនីដោយថាមពលខ្យល់ទាមទារនូវការអង្កេតបន្តទៀត ។

### 2.4.4 ថាមពលវារីអគ្គិសនីខ្នាតតូច

ផែនការមេ ផ្តល់អគ្គិសនីរបស់រាជរដ្ឋាភិបាល គឺពឹងផ្អែកជាសំខាន់ទៅលើ ការបង្កើតបណ្តាញអគ្គិសនីថ្នាក់ជាតិ និងការស្ថាបនាស្ថានីយ៍ថាមពលវារីអគ្គិសនី។ គំរោងថាមពលវារីអគ្គិសនីចំនួន ៣ ដែលត្រូវបានរៀបចំនាពេលថ្មីៗនេះ និងមានកំលាំងតំឡើងដល់ ១០០ MW ។ តាមច្បាប់របស់ប្រទេសកម្ពុជាការវាយតំលៃឥទ្ធិពលបរិស្ថាន (EIA) និងតំរូវអោយគ្រប់ស្ថានីយ៍ទាំងអស់មានកំលាំងតំឡើងលើសពី ៥ MW ។ កន្លែងមានប្រភពធនធានច្រើន ប្រទេសកម្ពុជាមានកំលាំងថាមពលដ៏ធំទី២ ស្ថិតនៅក្នុងមេគង្គក្រោម

ជាមួយកំលាំង១០,០០០ MW តាមការប៉ាន់ស្មាន (៩០% វាមានទីតាំងនៅមេគង្គនិងមាន១០% ស្ថិតនៅតំបន់ឆ្នេរក្នុងភាគនិរតី)។

ផ្អែកលើ RETs នៅអាស៊ី (២០០២) ដោយផ្តោតទៅលើប្រទេសកម្ពុជា ប្រទេសនេះមានកន្លែងវារីអគ្គិសនីចំនួនពីរ គីរីរម្យទី១ បានវិនិយោគដោយ CETIC (ជាមួយកំលាំងកើនឡើងដល់ ១២ MW) និងរោងចក្រវារីអគ្គីសនីជាមួយកំលាំងតំឡើងភ្លើង ១ MW ។ ការវិនិយោគផ្សេងទៀត របស់ CETIC គឺជាគំរោងគីរីរម្យទី៣។ វារីអគ្គិសនីនៅកំចាយ មានកំលាំងសរុប ១៨០ MW បច្ចុប្បន្នស្ថិត នៅក្រោមការដេញថ្លៃ។ តួលេខដែលត្រូវបានដកស្រង់ជាញឹកញាប់ ចំពោះសក្តានុពលវារីអគ្គិសនី ប្រទេស កម្ពុជាត្រូវបានផ្តល់ដោយរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB ដែលមានការជជែកពិភាក្សាគ្នាថា ទន្លេមេគង្គ និង ដៃទាំងអស់របស់វា មានសក្តានុពលសំរាប់បង្កើតថាមពល អគ្គិសនីកំលាំង ៨.៦ GW ( ADB, ១៩៩៩) ។ ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល កាន់តែមានភាពអន្ទះសារ ក្នុងការព្យាករណ៍របស់ខ្លួន អំពីសក្តានុពលវារីអគ្គិសនីរបស់ប្រទេសកម្ពុជាដែលមានកំលាំងប្រមាណ១០ GW ។ផែនការមេផ្តល់ថាមពលអគ្គិសនីមានការជជែកពិភាក្សាថាការផ្តល់ « ស្ថានភាពភូមិសាស្ត្រនិងទឹកភ្លៀងច្រើន » តំបន់ជាច្រើននៅប្រទេសកម្ពុជាមានលក្ខណៈអំណោយផលចំពោះការអភិវឌ្ឍន៍ គំរោងវារីអគ្គិសនីខ្នាតតូចកំលាំង១០០ kw ទៅ ៥ MW ។ព្រំដែនកំណត់ ៥ MW ឆ្លើយតបទៅនឹងកំលាំង តំឡើង អតិបរមា របស់ ស្ថានីយ៍មួយដែលមិនតំរូវអោយមានការវាយតំលៃផលប៉ះពាល់បរិស្ថាន ក្នុងពេលសាងសង់ ។ ក្រោមជំនួយឧបត្ថម្ភរបស់ JICA ក្នុងកិច្ចសហ ប្រតិ បត្តិការជាមួយ ក្រសួង ឧស្សាហកម្មរ៉ែនិងថាមពល និង EAC « តំរូវ ការទូទៅនៃគំរូបច្ចេកទេសថាមពលអគ្គិសនីសំរាប់ ព្រះរាជាណាចក្រកម្ពុជា » ត្រូវបានបង្កើតឡើង ។ ឯកសារនេះមានគោលបំណងចំបងៗដូចខាងក្រោមៈ

ដើម្បីបញ្ជាក់លក្ខណៈប្រតិបត្តិផ្នែករៀបចំ និងផ្នែកបច្ចេកទេសនៃសំភារៈ ថាមពលអគ្គិសនី ចរន្ត អគ្គិសនីតាមផ្ទះ និងសំភារៈអគ្គិសនី។

ដើម្បីអោយប្រាកដថា ច្បាប់មូលដ្ឋានសំរាប់ការផ្គត់ផ្គង់អគ្គិសនីមានភាពយុត្តិធម៌ ហើយមិនមាន ការរើសអើងសំរាប់អ្នកប្រើប្រាស់ទាំងអស់នៃប្រភេទដូចគ្នា។

ដើម្បីថែរក្សាកំរិតស្តង់ដាបច្ចេកទេស នៃការ ប្រើប្រាស់ថាមពលអគ្គិសនី ខ្សែ ភ្លើងនៅ តាម ផ្ទះ និងគ្រឿងបរិក្ខាអគ្គិសនីដែលត្រូវបានតំឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## 2.5 ការទទួលស្គាល់ប្រើប្រាស់ថាមពលថ្មី

តាមរយៈគោលការណ៍សហគ្រាសសេរី និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចាត់វិធានការណ៍យ៉ាងមុតមាំក្នុងការពង្រឹងស្ថាប័ន និងអភិបាលកិច្ចល្អ ។ ដំណើរការនៃការវិនិយោគទុននៅក្នុងប្រទេសកម្ពុជា គឺជាដំណើរការបើកទូលាយ និងដោយផ្ទាល់ របៀបនៃការចូលរួមរបស់អ្នកវិនិយោគទុនឯកជនតាមរយៈការប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និងការដេញថ្លៃប្រកបដោយតម្លាភាពសំរាប់គំរោងសំខាន់ៗ ដើរតាមវិធីសាស្រ្តថ្មីសំរាប់ការអភិវឌ្ឍន៍ និងការអនុម័តគំរោង វិនិយោគឯកជនក្នុងលក្ខណៈតម្លាភាព ។

ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល បានបង្ហាញថា មានតំរូវការចាំបាច់មួយសំរាប់ការគាំទ្រ បន្ថែមទៀតពីសំណាក់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអាចជំនះឧបសគ្គចំបងហើយលើកកំពស់បច្ចេកបច្ចេកវិជ្ជាថាមពលថ្មី និងសំរបសំរួលការចូលរួមពីផ្នែកឯកជន។ ក្រសួងឧស្សាហកម្មរ៉ែនិងថាមពលបានបញ្ជាក់ថា (១)ការអភិវឌ្ឍន៍ថាមពលថ្មី គឺជាសមាសភាគគន្លឹះមួយនៃយុទ្ធសាស្រ្តផ្តល់ថាមពលអគ្គិសនីតាមតំបន់ជនបទ របស់រាជរដ្ឋាភិបាលកម្ពុជា សំរាប់ការបង្កើតភ្លើង និង (២) ការគាំទ្រពីសំណាក់អ្នកផ្តល់ជំនួយសំរាប់ជួយការបណ្តុះបណ្តាលនិងបញ្ហាហិរញ្ញវត្ថុ គឺជាចំនុចគន្លឹះ និងសំខាន់បំផុតមួយក្នុងការលើកកំពស់ការអភិវឌ្ឍន៍ថាមពលប្រើប្រាស់សាជាថ្មីនៅក្នុងប្រទេសកម្ពុជា ។

**តារាង៦: សក្តានុពលភាពនៃការបង្កើតប្រភពថាមពលថ្មី**

| **ប្រភពបង្កើតថាមពល** | **ឱកាស** |
|---|---|
| ជិវម៉ាស់ | • មានវត្ថុធាតុដើមដូចជាអង្កាម្បចំបើង្បឧស្ម័នជីវ្បដូងប្រេង្បអាចម៍រណារ្ប ជំរៀកឈើ (ដើមកៅស៊ូ)<br>• មានបច្ចេកវិទ្យាជាច្រើនត្រូវបានដាក់បញ្ចូលគ្នា និងប្រើនៅកន្លែងផ្សេងៗគ្នា<br>• តំរូវការជាក់ស្តែងទៅតាមធនធាន់ ទៅលើការសិក្សាដែលអាចទៅរួចទៅ លើការប្រើប្រាស់បច្ចុប្បន្នត្រូវធ្វើការតាមដាន។ |
| ថាមពលព្រះអាទិត្យ | • ថាមពលមានគ្រប់គ្រាន់<br>• ការបង្ហាញច្បាស់លាស់តាមរយៈណាឡឿនិងអ្នកផ្សេងៗទៀត<br>• ឱកាសសំរាប់បំបែកបណ្តាញភ្លើងទៅតាមទីក្រុងតូចៗ |
| វារីអគ្គិសនី | • ថាមពលមានគ្រប់គ្រាន់. អាចបង្កើតភ្លើងនៅតាមស្រុកស្រែ<br>• Pico/micro អាចសំរបទៅតាមការប្រើប្រាស់នៅតាមភូមិតូចៗ តាមដងទន្លេ |

- Mini – គំរោងបានត្រូវបង្ហាញ និងធ្វើការតាមដានក្នុងប្រព័ន្ធស្រាវជ្រាវ

ថាមពលខ្យល់
- មានទំហំធំក្នុងការប្រើប្រាស់មាន (>500kw): 8 តំបន់មានបញ្ជាក់ជាគំរូល្អ ថាមពលឥឡូវត្រូវការពិនិត្យ និងធ្វើការស្រាវជ្រាវ
- មានទំហំតូចក្នុងការប្រើប្រាស់មាន (<500kW) គំរោងការបង្ហាញតាមរយៈ NEDO នៅក្នុងខេត្តតាកែវ ប៉ុន្តែកង្ហារមួយត្រូវខូច និងមានលក្ខណៈសមស្របអាចធ្វើបាន
- ការតាមដានបន្ថែមជាគំរូវការចាំបាច់

នៅពេលបច្ចុប្បន្ននេះ ប្រព័ន្ធផ្គត់ផ្គង់ថាមពលនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមានអង្គភាពថាមពលទោលខ្នាតតូច។ ដូចនេះវាពិតណាស់ បណ្តាញប្រព័ន្ធថាមពលអគ្គិសនីទូទាំងប្រទេស ជាតំរូវការចាំបាច់ដែលអាចភ្ជាប់ទៅដល់អ្នកបង្កើតផលិតថាមពលអគ្គិសនី និង អ្នកចែកចាយ ។ បន្ថែមលើសពីនេះទៀតកង្វះថាមពលអគ្គិសនី ជាហេតុនាំអោយតំលៃភ្លើងខ្ពស់ ដែលគួរតែត្រូវធ្វើការដោះស្រាយ។ ក្រៅពីទីក្រុងភ្នំពេញ និងតាមទីរួមខេត្តមួយចំនួន មានសេវាថាមពលអគ្គិសនី តំបន់មួយផ្នែកធំនៅប្រទេសកម្ពុជា ការផ្គត់ផ្គង់ថាមពលអគ្គិសនីត្រូវបានចែកចាយដោយសហគ្រិនឯកជនខ្នាតតូច មានតំលៃសេវា នូវពី ១០០០-១៥០០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង។
របាយការណ៍ស្តីពីការអភិវឌ្ឍន៍ប្រភពថាមពលថ្មីនៅក្នុងប្រទេសកម្ពុជា បង្ហាញនូវភាពយឺតយ៉ាវ ដោយសារមូលហេតុដូចខាងក្រោមៈ

- ខ្វះខាតបទពិសោធន៍ផ្នែកថាមពល
- គំរោងនិងគោលនយោបាយមានដែនកំណត់
- ខ្វះខាតការឧបត្ថម្ភសំរាប់ផ្នែកនេះ
- ខ្វះខាតពត៌មាន និងទិន្នន័យដែលត្រូវដឹង និង
- ការប្រើប្រាស់ប្រភពថាមពលថ្មីនៅមានលក្ខណ» ស្ហួចស្តើង មិនបានបញ្ចូលទៅក្នុងការចែកចាយការផ្គត់ផ្គង់ថាមពលដែលផ្អែកលើប្រេងឥន្ធនៈ។

# 3 ពតិមានតាមការចុះធ្វើបញ្ជីសំណួរស្ទាបស្ទង់

## 3.1 ក្រុមគោលដៅ

យោងទៅតាមប្រទេសកម្ពុជា នៅតែមានកន្លែងជាច្រើនពុំទាន់អាចប្រើភ្លើងអគ្គិសនីបានស្រួលនៅឡើយ និងមានតំលៃខ្ពស់ ក្នុង ១ គីឡូ វ៉ាត់ម៉ោង ជាពិសេសនៅតាមតំបន់ជនបទ ហើយតំបន់ដែលមិនមានបណ្តាញភ្លើង។ ដើម្បីជាជំនួយសំរាប់អោយមានពតិមានច្បាស់នៅក្នុងតំបន់ទីក្រុង ដូចជាភ្នំពេញ ហើយក៏ដូចជាតំបន់ជនបទ អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED) បានជ្រើសរើសយកក្រុមគោលដៅនៅក្នុងខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ដើម្បីធ្វើបញ្ជីសំណួរស្ទាបស្ទង់ ក្នុងចំណោម ១០០០ គ្រួសារ និងទិន្នន័យមួយចំនួនដកស្រង់ពីគេហទំព័រ (website) ។

### 3.1.1 ភេទ Gender

**តារាង៧: ប្រជាពលរដ្ឋនៅតាមខេត្ត**

| តំបន់ខេត្តស្រុក | ឃុំ | ប្រជាជន | គ្រួសារ | ភូមិ | បុរស | ស្ត្រី | កុមារ |
|---|---|---|---|---|---|---|---|
| ពោធិ៍សាត់ | | | | | | | |
| ស្រុកសំពៅមាស | ឃុំស្វាយអាត់ | ៤៤៣៣ | ៨៩៤ | ៥ | ១៨៣៦ | ១៥៧៧ | ១០២០ |
| | ឃុំផ្ទះព្រៃ | ១៦៥២៤ | ៣២២៦ | ១០ | ៦៩៣៩ | ៦៨៨៩ | ២៦៩៦ |
| ស្រុកភ្នំក្រវាញ | ឃុំលាច | ៨៥៨៣ | ១៦៤៣ | ៨ | ៣០១៤ | ៣៦៩៧ | ១៨៧២ |
| | ឃុំរកាត | ៣៩៩៧ | ៧៨២ | ៤ | ១៤០១ | ១៩០០ | ៦៩៦ |
| កំពង់ឆ្នាំង | | | | | | | |
| ស្រុករលាប្អៀរ | ឃុំទឹកហូត | ៧៩៩៨ | ១៥២៦ | ១០ | ៣៣២៣ | ៣៥៤៨ | ១១២៧ |
| | ឃុំជើងគ្រាវ | ៦៤២៥ | ១៣៧៩ | ១១ | ២៧២៦ | ២៤៨៦ | ១២១៣ |
| ស្រុកកំពង់ឆ្នាំង | ឃុំផ្អេរ | ៥៧៩៩ | ១១០៥ | ៤ | ៨១៥ | ២៩៣២ | ២០៥២ |
| ស្វាយរៀង | | | | | | | |
| ស្រុកស្វាយជ្រុំ | ឃុំចំបក់ | ៩៧០២ | ១៩៩៧ | ១០ | ២១១៤ | ៤២៩៦ | ៣២៩២ |
| | ឃុំគ្រួស | ១១២៨៩ | ២៩៦៤ | ១១ | ៣២៤២ | ៤១៩១ | ៣៨៥៦ |
| កំពង់ចាម | | | | | | | |
| ស្រុកពញាក្រែក | ឃុំកោងកាង | ១៤៦៩០ | ៣០០១ | ១៦ | ៣៧៦១ | ៣៩៦១ | ៦៩៦៨ |

| | | | | | | |
|---|---|---|---|---|---|---|
| សរុប | ៨៩៤៤០ | ១៨៥១៧ | ៨៩ | ២៩១៧១ | ៣៥៤៧៧ | ២៤៧៩២ |

## 3.1.2 ប្រភពចំណូលសំខាន់សំរាប់គ្រួសារនិមួយៗ

### 3.1.2.1 ខេត្តពោធិ៍សាត់

តារាង៨: ចំនួនអ្នកដែលត្រូវបានធ្វើសម្ភាសន៍នៅខេត្តពោធិ៍សាត់

| ឃុំ | ស្វាយអាត់ | ផ្ទះព្រៃ | រការ | លាច | ពោធិ៍សាត់ | ភាគរយ |
|---|---|---|---|---|---|---|
| កសិករ | ១៦ | ១៣ | ១៩ | ១៥ | ៦៣ | ២៥.២% |
| គ្រូបង្រៀន | ៦ | ៥ | ៦ | ១០ | ២៧ | ១០.៨% |
| ជំនួញខ្នាតតូច | ៧ | ១៧ | ៤ | ៥ | ៣៣ | ១៣.២% |
| មន្ត្រីរាជការ | ១០ | ១១ | ៥ | ៥ | ៣១ | ១២.៤% |
| សិប្បកម្ម | ៥ | ៦ | ១០ | ៩ | ៣០ | ១២% |
| ផ្សេងៗ | ១៦ | ១៨ | ១៦ | ១៦ | ៦៦ | ២៦.៤ % |
| សរុប | ៦០ | ៧០ | ៦០ | ៦០ | ២៥០ | ១០០% |

### 3.1.2.2 ខេត្តកំពង់ឆ្នាំង

តារាង៩: ចំនួនអ្នកដែលបានធ្វើសម្ភាសន៍នៅខេត្តកំពង់ឆ្នាំង

| ឃុំ | ជើងគ្រាវ | ផ្សេរ | ឃុំទឹកហូត | កំពង់ឆ្នាំង | ភាគរយ |
|---|---|---|---|---|---|
| កសិករ | ៥០ | ៣០ | ៤៥ | ១២៥ | ៥០% |
| គ្រូបង្រៀន | ៥ | ១០ | ១២ | ២៧ | ១០.៨% |
| ជំនួញខ្នាតតូច | ៧ | ៥ | ៧ | ១៩ | ៧.៦% |
| មន្ត្រីរាជការ | ៥ | ១៥ | ១០ | ៣០ | ១២% |
| សិប្បកម្ម | ១ | ២ | ២ | ៥ | ២% |
| ផ្សេងៗ | ១២ | ១៨ | ១៤ | ៤៤ | ១៧.៦% |
| សរុប | ៨០ | ៨០ | ៩០ | ២៥០ | ១០០% |

### 3.1.2.3 ខេត្តស្វាយរៀង

**តារាង១០: ចំនួនអ្នកដែលបានធ្វើសម្ភាសន៍នៅខេត្តស្វាយរៀង**

| ឃុំ | គ្រួស | ចំបក់ | ស្វាយរៀង | ភាគរយ |
|---|---|---|---|---|
| កសិករ | ៦៩ | ៤៥ | ១១៤ | ៤៥.៦% |
| គ្រូបង្រៀន | ២៦ | ១៩ | ៤៥ | ១៨% |
| ជំនួញខ្នាតតូច | ២១ | ១២ | ៣៣ | ១៣.២% |
| មន្ត្រីរាជការ | ២៣ | ១១ | ៣៤ | ១៣.៦% |
| សិប្បកម្ម | ១ | ១ | ២ | ០.៨% |
| ផ្សេងៗ | ១០ | ១២ | ២២ | ៨.៨% |
| សរុប | ១៥០ | ១០០ | ២៥០ | ១០០% |

### 3.1.2.4 ខេត្តកំពង់ចាម

**តារាង១១: ចំនួនអ្នកដែលបានធ្វើសម្ភាសន៍នៅខេត្តកំពង់ចាម**

| ឃុំ | កោងកាង | កំពង់ចាម | ភាគរយ |
|---|---|---|---|
| កសិករ | ១៥០ | ១៥០ | ៦០% |
| គ្រូបង្រៀន | ១៣ | ១៣ | ៥.២% |
| ជំនួញខ្នាតតូច | ៤៩ | ៤៩ | ១៩.៦% |
| មន្ត្រីរាជការ | ១៦ | ១៦ | ៦.៤% |
| សិប្បកម្ម | ២ | ២ | ០.៨% |
| ផ្សេងៗ | ២០ | ២០ | ៨% |
| សរុប | ២៥០ | ២៥០ | ១០០% |

### 3.1.2.5 តារាងប្រៀបធៀប

**តារាង១២: ចំនួនអ្នកដែលបានធ្វើសម្ភាសន៍នៅខេត្តទាំងបួន**

| ខេត្ត | ពោធិ៍សាត់ | កំពង់ឆ្នាំង | ស្វាយរៀង | កំពង់ចាម | សរុប | ភាគរយ |
|---|---|---|---|---|---|---|
| កសិករ | ៦៣ | ១២៥ | ១១៤ | ១៥០ | ៤៥២ | ៤៥ ២% |

| | | | | | | |
|---|---|---|---|---|---|---|
| គ្រូបង្រៀន | ២៧ | ២៧ | ៤៥ | ១៣ | ១១២ | ១១ ២% |
| ជំនួញខ្នាតតូច | ៣៣ | ១៩ | ៣៣ | ៤៩ | ១៣៤ | ១៣ ៤% |
| មន្ត្រីរាជការ | ៣១ | ៣០ | ៣៤ | ១៦ | ១១១ | ១១ ១% |
| សិប្បកម្ម | ៣០ | ៥ | ២ | ២ | ៣៩ | ៣ ៩% |
| ផ្សេងៗ | ៦៦ | ៤៤ | ២២ | ២០ | ១៥២ | ១៥ ២% |
| សរុប | ២៥០ | ២៥០ | ២៥០ | ២៥០ | ១០០០ | ១០០% |




**រូបភាពទី១: ប្រភពចំណូលក្នុងចំណោមក្រុមគោលដៅតាមខេត្តទាំងបួននៅកម្ពុជា**

បញ្ជីសំណួរបានធ្វើទៅលើ ១០០០ គ្រួសារ។ គេបានផ្តល់ពត៌មានអំពីចំណូលផ្ទាល់ទៅក្នុង ៤ខេត្ត មាន ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។ តាមពត៌មានដែលទទួលបានអត្រាចំណូលចំបងតាមរយៈធ្វើស្រែ។ ៤៥.២% ដែលបានបញ្ជាក់ថាជាកសិករ ហើយអ្នកធ្វើជំនួញ តាមបែបគ្រួសារត្រូវបានកត់សំគាល់ថាមានប្រភពចំណូល ១៣.៤% គ្រួសារដទៃទៀតទទ្ទឹមនឹង ១១.២% ជាគ្រូបង្រៀន និង ១១.១% ក្នុងមន្ត្រីរាជការ ។ ចំណែកចំនួនចំណូលតាមសិប្បកម្មមានតែ ៣.៩% ទទ្ទឹមនឹងចំណូលតាមផ្សេងៗ* មាន ១៥.២%។

## សំគាល់

ចំណូលតាមផ្សេងៗ* =  មានចំណូលតាមផ្នែកខុសគ្នាជាច្រើនដូចជា កម្មករ មេផ្ទះ អ្នករត់តាក់ស៊ី សិស្ស និស្សិត និងអ្នកអត់ការងារធ្វើ សរុបមាន១៥.២% ។

### 3.1.3 តំបន់រស់នៅផ្សេងៗគ្នា

ខេត្តពោធិ៍សាត់ចែកចេញជា ៦ស្រុក ដែលមានស្រុកបាកាន ស្រុកកណ្ដៀង ស្រុកក្រគរ ស្រុកភ្នំក្រវាញ ស្រុកសំពៅមាស (ស្រុកធំជាងគេ) និងស្រុកវាលវែង។ អ្នកដែលរស់នៅក្នុងខេត្តពោធិ៍សាត់មានចំនួន ៣៦០ ៤៤៥ នាក់។ ២ស្រុកត្រូវបានជ្រើសរើសយកសំរាប់ធ្វើសំណួរស្ទាបស្ទង់ និងភ្នំក្រវាញ ជាមួយ ៤ឃុំ មានឃុំស្វាយអាត់ ឃុំផ្ទះព្រៃ ឃុំរកាត និងឃុំលាច។ ក្រុមគោលដៅមានចំនួន ២៥០ គ្រួសារ ។ ខេត្តកំពង់ឆ្នាំងចែកចេញជា ៨ស្រុក ដែលមានស្រុកបរិបូរណ៌ ស្រុកជុលគីរី ស្រុកកំពង់ឆ្នាំង ស្រុកកំពង់លាង ស្រុកតាឡាច ស្រុករលាប្អៀរ ស្រុកសាមគ្គីមានជ័យ និងស្រុកទឹកផុស។ សរុបចំនួនប្រជា_ជនរស់នៅក្នុងខេត្តកំពង់ឆ្នាំងមាន ៤១៧ ៦៣៩នាក់។ ស្រុកចំនួន២ ត្រូវបានជ្រើសរើសយកធ្វើសំណួរស្ទាបស្ទង់មានស្រុកកំពង់ឆ្នាំង និងស្រុករលាប្អៀរជាមួយនឹង៣ឃុំគឺ ឃុំជើងគ្រាវ ឃុំផ្អេរ និងឃុំទឹកហូត ក្រុមគោលដៅមានចំនួន២៥០គ្រួសារ។

ខេត្តស្វាយរៀងចែកចេញជា ៧ស្រុក ដែលមាន ស្រុកចន្ទ្រា ស្រុកកំពង់រោទ្ធ ស្រុករំដួល ស្រុករមាសហែក ស្រុកស្វាយជ្រុំ ស្រុកស្វាយទាប។ សរុបចំនួនប្រជាជនក្នុងខេត្តស្វាយរៀងមាន ៤៧៨,២៥២នាក់។ ស្រុកចំនួន១ គឺស្រុកស្វាយជ្រុំ ជាមួយនឹង២ឃុំ ត្រូវបានជ្រើសរើសជាក្រុមគោលដៅដែលមាន ២៥០ គ្រួសារផងដែរ។

ខេត្តកំពង់ចាមចែកជា ១៧ស្រុកដែលមាន ស្រុកបន្ទាយ ស្រុកចំការលើ ស្រុកជើងព្រៃ ស្រុកដំបែរ ស្រុកកំពង់ចាម ស្រុកកំពង់សៀម ស្រុកគងមាស ស្រុកកោះសុទិន ស្រុកក្រូចឆ្មារ ស្រុកមេមត់ ស្រុកអូររាំងឪ ស្រុកពញាក្រែក ស្រុកព្រៃឈរ ស្រុកស្រីសន្ធរ ស្រុកស្ទឹងត្រាំង និងស្រុកត្បូងឃ្មុំ។

ចំនួនប្រជាជនរស់នៅសរុបនៅក្នុងខេត្តកំពង់ចាមមាន ១.៦០៨.៩១៤នាក់។ ស្រុកចំនួន១ គឺស្រុកពញាក្រែក ជាមួយនឹងឃុំ១ គឺឃុំកោងកាង ត្រូវបានជ្រើសរើសជាក្រុមគោលដៅជាមួយនិង ២៥០គ្រួសារ។

## 3.2 ទិន្នន័យសង្គមកិច្ច_សេដ្ឋកិច្ច

តាមការធ្វើបញ្ជីសំណួរស្ទាបស្ទង់បានផ្ដល់ ទិន្នន័យសង្គមកិច្ច_សេដ្ឋកិច្ច នៅចរិកលក្ខណៈខុសគ្នាជាច្រើនទៅតាមតំបន់ក្រុមគោលដៅ។ប្រទេសកម្ពុជាស្ថិតនៅក្នុងប្រទេសដែលបានអភិវឌ្ឍតិចតួច។ នៅក្នុងឆ្នាំ ១៩៩៩ ផលិតផលក្នុងស្រុកមានចំនួន៣.១កោដដុល្លា ដែលនាំមកនូវផលិតផលក្នុងស្រុក ១ឯកតា

២៧០ដុល្លា ក្នុងចំណោមក៏រិតទាបជាងគេនៅក្នុងពិភពលោក។ សេដ្ឋកិច្ចប្រទេសនេះដើបឡើងយ៉ាងឆាប់រហ័ស និងមានផលិតផលក្នុងស្រុក ១ឯកតា តាមការប្រមាណគឺ ២៦០០ដុល្លាអាមេរិក ក្នុងឆ្នាំ២០០៦។ ទំរង់រូបទី២ បង្ហាញពីអត្រាក្រីក្រនៅភាពខុសគ្នាតាមផ្នែកនៃប្រទេស។







**រូបភាពទី២:** **អត្រាភាពក្រីក្រទៅតាមតំបន់ក្នុងប្រទេសកម្ពុជា**

### 3.2.1 ចំណូលគ្រួសារតាមក្រុមគោលដៅផ្សេងគ្នា

បញ្ជីសំណួរស្ទាបស្ទង់ទិន្នន័យនៃចំណូលគ្រួសារជាមួយនឹងក្រុមគោលដៅក្នុងខេត្តផ្សេងៗដែលនៅក្នុងតារាងខាងក្រោម៖

**តារាង១៣: អត្រាចំណូលជាមធ្យមក្នុងមួយគ្រួសារ**

| អត្រាចំណូលជាមធ្យម | ពោធិ៍សាត់ | ស្វាយរៀង | កំពង់ឆ្នាំង | កំពង់ចាម |
|---|---|---|---|---|
| កសិករ | ២៥$ _៥០$ | ២០$_៥០$ | ២០$_៥០$ | ២០$_៥០$ |
| គ្រូបង្រៀន | ២៥$_៧០$ | ២០$_៨៥$ | ២៥$_៨០$ | ៣០$_១០០$ |
| ជំនួញធុនតូច | ១២៥$_២០០$ | ៥០$_១៨០$ | ៥០$_១៥០$ | ១៥០$_៣០០$ |
| មន្ត្រីរាជការ | ១៥$_១២៥៖ | ២០$_១០០$ | ២០$_១០០$ | ២០$_១៥០$ |
| សិប្បកម្ម | ៣០៖$_១០០$ | ៣០$_៥០$ | ៣០$_៥០$ | ៣០$_១០០$ |
| ផ្សេងៗ | ៣០$_៥០$ | ២៥$_៥០$ | ២៥$_៥០$ | ២៥$_៥០$ |

តារាងខាងលើបង្ហាញពីចំណូលជាមធ្យមទៅតាមគ្រួសារផ្សេងៗគ្នាក្នុង ៤ ខេត្ត ។ សំរាប់គ្រួសារកសិករ ចំណូលគិតជាមធ្យមរវាងពី ២០ដុល្លា ទៅ ៥០ ដុល្លា។ យោងទៅតាមលទ្ធផលបញ្ជីសំណួរ នៃអង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា មាន ៤៥% នៃគ្រួសារមានចំណូលតាមការធ្វើស្រែ ដែលជាប្រភពចំណូលដ៏សំខាន់។ ចំណូលជាមធ្យមរបស់គ្រួសារកសិករ មិនមានអ្វីខុសពីចំណូលជាមធ្យមក្នុគ្រួសារដទៃទៀត យោងទៅតាមបញ្ជីសំណួរ ថ្វីបើចំណូលជាអតិបរមានៃគ្រួសារ ទំនងដូចជាមានលក្ខណៈទាបជាងក្រុមដទៃទៀត។

គ្រួសារគ្រូបង្រៀនតាមចំណូលផ្សេងៗពីគ្នារវាង ២០ដុល្លា ទៅ ១០០ដុល្លា ជាមួយការបំរែបំរួលតិចតួចទៅតាមតំបន់។ ភាគច្រើនគ្រូបង្រៀននៅកម្ពុជា ព្យាយាមបន្ថែមចំណូលតាមការបង្រៀនគួរជាលក្ខណៈឯកជន ។

អ្នកមានបើកជំនួញផ្ទាល់ខ្លួនជាច្រើននៅក្នុងទីផ្សារសេរីនៅប្រទេសកម្ពុជា ដែលត្រូវបានរំពឹងទុកថានឹងមានឥទ្ធិពលទៅនឹងការរីកចំរើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជា។ យោងទៅតាមបញ្ជីសំណួរពីចំណូលផ្សេងៗ ពួ គ្នារវាង ៥០ ដុល្លា ទៅ ៣០០ ដុល្លា។ វាអាស្រ័យទៅតាមតំបន់ផងដែរ នៃការបើកជំនួញផ្ទាល់ខ្លួនដូចបានឃើញតាមតារាងខាងលើ។

